


# នៅពីក្រោយផ្ទាំងអេក្រង់

# ការយល់ដឹងអំពីការប្រើប្រាស់អំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញនៅកម្ពុជា

ទាញយករបាយការណ៍ពេញនៅទីនេះ



## 1. ការយល់ដឹងអំពីការប្រើប្រាស់អំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ (OGBV)



ជារួម ការយល់ដឹងពីអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញនៅមានកម្រិត។ មានតែ ៧% នៃអ្នកឆ្លើយតបការស្ទង់មតិប៉ុណ្ណោះដែលគិតថាប្រជាជនកម្ពុជាមានការយល់ដឹងច្បាស់ពីប្រធានបទនេះ។ ទោះបីជា ១៤%នៃអ្នកឆ្លើយតបការស្ទង់មតិធ្លាប់លឺអំពីទម្រង់ខ្លះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ អ្នកឆ្លើយតបភាគច្រើនមិនធ្លាប់ដឹងពីពាក្យ "អំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ" ឬផលប៉ះពាល់របស់អំពើហិង្សានេះទាំងក្នុង និងក្រៅប្រព័ន្ធអនឡាញ។ លើសពីនេះទៅទៀតអ្នកចូលរួមការស្រាវជ្រាវមួយចំនួនក៏បានលើកឡើងពីការមិនយល់ច្បាស់ពីភាពខុសគ្នារវាងអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) និង OGBV។

<u>រូបទី៤៖</u> ភាគរយនៃអ្នកចូលរួមឆ្លើយតបការស្ទង់មតិដែលធ្លាប់បានលឺពីអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ (ឧ. ការប្រមាថមាក់ងាយតាមអនឡាញ ការប្រើប្រាស់សម្ដីស្អប់ខ្ពើម ការផ្សព្វផ្សាយរូបភាពស្និទ្ធស្នាលដោយមិនមានការព្រមព្រៀង។ល។)




កម្រិតនៃការយល់ដឹងក៏មានភាពខុសគ្នាក្នុងចំណោមក្រុមផ្សេងៗគ្នា។ ឧ. ក្រុមអ្នកស្រលាញ់ភេទដូចគ្នាភាគច្រើនធ្លាប់លឺពីOGBV ហើយមួយចំនួនក៏ធ្លាប់ជួបប្រទះអំពើហិង្សានេះដោយផ្ទាល់។ ជាហេតុ អ្នកចូលរួមការស្រាវជ្រាវភាគច្រើនគិតថា ស្ត្រី បុគ្គលក្រុមអ្នកស្រលាញ់ភេទដូចគ្នា និងជនមានពិការភាពគឺជាក្រុមដែលងាយទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ។

*"ពួកគេដែលជាបុគ្គលស្រឡាញ់ភេទដូចគ្នា ក៏ជួបប្រទះ OGBV ច្រើនដែរ ដែលវាសឹងតែក្លាយទៅជារឿងធម្មតាទៅហើយ។ នៅពេលដែលពួកគេនិយាយពីរឿងនេះ មនុស្សជាច្រើននិយាយថា 'វាធម្មតាទេ ក្រុមស្រឡាញ់ភេទដូចគ្នាគឺអញ្ចឹងឯង។' ដោយសារតែសង្គមយល់ឃើញថាក្រុមអ្នកស្រឡាញ់ភេទដូចគ្នា គឺជាក្រុមដែលសកម្មទៅលើរឿងផ្លូវភេទ ការព្រួយបារម្ភរបស់ពួកគេអំពីការបៀតបៀនតាមប្រព័ន្ធអនឡាញជារឿយៗត្រូវបានគេអើពើ។" (YM7)*



## មូលហេតុឬសគល់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ

**រូបទី៨៖ ការយល់ឃើញរបស់អ្នកឆ្លើយតបទាក់ទងនឹងមូលហេតុដែលមនុស្សភាគច្រើនមិនមានការយល់ដឹងពីOGBV**




ការសិក្សាស្រាវជ្រាវនេះបានសម្គាល់ មូលហេតុ ឬឫសគល់នៃ OGBVចំនួន ៤គឺ៖ (១) ភាពមានកម្រិតនៃអក្ខរកម្មឌីជីថល (២) កត្តាអំណាច (៣) បទដ្ឋានយេនឌ័រ និងការរំពឹងទុករបស់សង្គម និង (៤) ភាពអនាមិក និងលក្ខណៈរបស់បណ្ដាញសង្គម។

ភាពមានកម្រិតនៃអក្ខរកម្មឌីជីថល និងកង្វះការអប់រំស្ដីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញនាំឱ្យមានផលលំបាកក្នុងការសម្គាល់អំពើហិង្សា និងវិធីក្នុងការរាយការណ៍ ព្រមទាំងនាំឱ្យការប្រើប្រាស់ OGBV ក្លាយជារឿងធម្មតា។ បន្ថែមពីនេះ កត្តាអតុល្យភាពនៃអំណាច ដែលមានឫសគល់ពីបទដ្ឋានយេនឌ័រ និងការរំពឹងទុករបស់សង្គមបង្កើតឱ្យមានឋានានុក្រមនៅតាមប្រព័ន្ធអនឡាញ។ ជាលទ្ធផល អ្នកដែលមានអំណាចបានប្រើប្រាស់អំណាចនោះទៅបៀតបៀន អ្នកដែលពួកគេយល់ថាខ្សោយជាងខ្លួនតាមប្រព័ន្ធអ៊ីនធឺណិត និងបណ្ដាលឱ្យស្ត្រី និងបុគ្គលដែលស្រឡាញ់ភេទដូចគ្នា ត្រូវបានគេវិនិច្ឆ័យ និងទទួលការមាក់ងាយតាមអនឡាញ។ ចុងក្រោយ ភាពអនាមិក អវត្តមាននូវការប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់ និងភាពងាយស្រួលរបស់បណ្ដាញសង្គម ជម្រុញឲ្យមានអំពើហិង្សាតាមប្រព័ន្ធអនឡាញ និងដាក់បន្ទុកបន្ថែមលើយន្តការណ៍រាយការណ៍ដែលមានស្រាប់។

*មនុស្សខ្លះគិតថា អ្នកដែលកើតមកមានលក្ខណៈខុសពីពួកគេ គឺជាមនុស្សអាក្រក់។ គំនិតអភិរក្សទាំងនេះធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃ និងនាំឱ្យមាន OGBV។  (YW1)*

## 2. បទពិសោធន៍ទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ

៣១.៧៨% នៃអ្នកឆ្លើយតបការស្ទង់មតិធ្លាប់ទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ ហើយ៥៥.០៤% ស្គាល់អ្នកដែលធ្លាប់ទទួលរងអំពើហិង្សានេះ។ ទម្រង់នៃអំពើហិង្សាដែលកើតមានឡើងញឹកញាប់ជាងគេគឺ (១) ការគំរាមកំហែងតាមអ៊ីនធឺណិត និងការប្រើពាក្យពេចន៍ដែលមានលក្ខណៈស្អប់ខ្ពើម (២) ការកេងប្រវ័ញ្ច និង/ឬការបៀតបៀនផ្លូវភេទតាមប្រព័ន្ធអនឡាញ និង (៣) ការឆបោកតាមប្រព័ន្ធអនឡាញដូចជាការឆបោកផ្នែកហិរញ្ញវត្ថុ និងការបោកប្រាស់ស្នេហាតាមប្រព័ន្ធអ៊ីនធឺណិត។



រូបទី១៣៖ ទម្រង់នៃOGBV ដែលអ្នកឆ្លើយតបធ្លាប់ទទួលរង ឬស្គាល់អ្នកដែលធ្លាប់ទទួលរង (n=114)




ទម្រង់នៃអំពើហិង្សាទាំងនេះប្រព្រឹត្តឡើងដោយអ្នកដែលជនរងគ្រោះស្គាល់ អតីតដៃគូរបស់ជនរងគ្រោះ ក៏ដូចជាអ្នកដទៃតាមប្រព័ន្ធអនឡាញ។ ក្រុមបុគ្គលមួយចំនួនទទួលរងបទពិសោធន៍ខុសៗគ្នា។

*ខ្ញុំធ្លាប់មានបទពិសោធន៍មួយជាមួយមនុស្សម្នាក់ដែលខ្ញុំធ្លាប់រស់នៅជាមួយ។ បន្ទាប់ពីយើងឈប់រស់នៅជាមួយគ្នា គាត់បានចែករំលែករូបថតស្និទ្ធស្នាលរបស់យើងតាមប្រព័ន្ធអនឡាញ ហើយថែមទាំងប្រើវានៅលើបណ្ដាញសង្គមផ្ទាល់ខ្លួនរបស់គាត់ទៀតផង។ ខ្ញុំគិតថានោះគឺជាទង្វើមួយក្នុងចំណោមសកម្មភាពផ្សេងទៀតដែលទាក់ទងនឹងអំពើហិង្សាតាមប្រព័ន្ធអនឡាញ។ (YL-SR9)*.*

*សម្រង់ពាក្យសម្ដីនេះត្រូវបានកែសម្រួលបន្តិចបន្តួចសម្រាប់ការការពារ។ ព័ត៌មានដែលកំណត់អត្តសញ្ញាណត្រូវបានកែប្រែ ដោយមិនបានផ្លាស់ប្ដូរអត្ថន័យដើមរបស់អ្នកចូលរួម។



## បទពិសោធន៍ចម្រុះទាក់ទងនឹង OGBV

*"នៅពេលដែលខ្ញុំឃើញមនុស្សស្រីពាក់សម្លៀកបំពាក់ដែលនាងចូលចិត្ត ប៉ុន្តែសម្លៀកបំពាក់នឹងខ្លីបន្តិច [លើប្រព័ន្ធសង្គម] មនុស្សប្រុសភាគច្រើនចូលទៅបញ្ចេញមតិថា 'ម្នាក់ស្រីនេះធ្វើខ្លួនដូចនារីរកស៊ីផ្លូវភេទ (......)។' ពួកគេបន្ទោសមនុស្សស្រី ទោះបីពួកគេជាអ្នកគិតបែបនោះក៏ដោយ។" (ZM-SR14)*

*"នៅពេលដែលបុគ្គលស្រឡាញ់ភេទដូចគ្នារៀបការជាមួយគ្នា មានមតិសឹងតែ ៥០-៦០% ហើយដែលនិយាយចំអកថា តម្លៃប្រេងឡើងថ្លៃដោយសារតែពួកគេ។" (YL-C5)*

*"ពួកយើងត្រូវបានគេប្រមាថតាមប្រព័ន្ធអនឡាញ ដោយសារតែពួកយើងជាជនជាតិដើមពូនង។ មនុស្សបាននិយាយពាក្យដែលធ្វើឱ្យពួកយើងឈឺចាប់ជាច្រើន ដូចជាប្រៀបធៀបអត្តចរិកមិនល្អរបស់ប្ដីពួកគេមកកាន់ពូនង។ ការបញ្ចេញមតិបែបនេះពិតជាឈឺចាប់។ (.....) វាជាការឈឺចាប់ដែលត្រូវបានគេមិនគោរពបែបនេះ។" (ZM-IP2)*

*"ខ្ញុំបានឃើញការជេរប្រមាថនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមទាក់ទងនឹងពិការភាពរបស់ខ្ញុំ។ នៅពេលដែលមនុស្សមិនយល់ស្របជាមួយនឹងបុគ្គលិកលក្ខណៈនៅលើអ៊ីនធឺណិត ពួកគេចំអក ឬប្រមាថរូបរាងជំនួសឱ្យការពិភាក្សាអំពីបញ្ហាដែលត្រូវពិភាក្សា។" (YW-PwD3)*

## 3. ផលជះ និងផលប៉ះពាល់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ

អំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញមានផលជះទាំងក្នុង និងក្រៅប្រព័ន្ធអនឡាញ។ ផលជះទាំងនោះរួមមាន ផលប៉ះពាល់លើសុខភាពផ្លូវចិត្ត ការធ្វើការចាប់ពិរុទ្ធខ្លួនឯង និងការផ្តាច់ខ្លួនឲ្យនៅតែឯង ក៏ដូចជាការជួបការរើសអើងទាំងក្នុង និងក្រៅប្រព័ន្ធអនឡាញ។ លើសពីនេះទៀត ជនរងគ្រោះក៏ជួបប្រទះផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ និងការឃាឃី រួមទាំងការគំរាមកំហែងផ្លូវកាយ។

### ផលជះក្នុងប្រព័ន្ធអនឡាញ នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ

**រូបទី ១៤៖ ការយល់ឃើញរបស់អ្នកឆ្លើយតបការស្ទង់មតិលើផលជះក្នុងប្រព័ន្ធអនឡាញ នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញមកលើពួកគេ ឬអ្នកដែលគេស្គាល់**




*“ពួកគេរក្សាភាពស្ងាត់ស្ងៀម មិនចង់ចេញទៅក្រៅ ឬចូលរួមសកម្មភាពផ្សេងៗ ដោយសារតែបទពិសោធន៍របស់ពួកគេដែលជួបប្រទះការបៀតបៀនតាមប្រព័ន្ធអនឡាញ។ វាជាការបាត់បង់សេរីភាពក្នុងជីវិតប្រចាំថ្ងៃ។” (YW-C3)*

### ផលជះក្រៅប្រព័ន្ធអនឡាញ នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ

រូបទី១៥៖ ការយល់ឃើញរបស់អ្នកឆ្លើយតបការស្ទង់មតិលើផលជះក្រៅប្រព័ន្ធអនឡាញ នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញមកលើពួកគេ ឬអ្នកដែលគេស្គាល់




*“វាប៉ះពាល់ដល់ទំនុកចិត្តរបស់ខ្ញុំមកលើខ្លួនឯង និងបណ្តាលឲ្យមានការព្រួយបារម្ភលើសុវត្ថិភាពរបស់ខ្លួនឯង ដោយសារតែខ្ញុំមិនដឹងថាអ្នកនៅក្នុងប្រព័ន្ធបណ្តាញសង្គមនឹងឆ្លើយតបយ៉ាងណា។ ខ្ញុំធ្លាប់ទទួលបានការមាក់ងាយពីមុន។ វាមានអារម្មណ៍ថារឹតត្បិតណាស់។” (ZW-I6)*





## 4. ការទទួលបានការគាំទ្រ និងបញ្ហាប្រឈមក្នុងការស្វែងរកការគាំទ្រ

រូបទី ១៨៖ ប្រព័ន្ធគាំទ្រដែលអ្នកមានបទពិសោធន៍ទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ (ឬអ្នកដែលគេស្គាល់) បានស្វែងរកជំនួយ




អ្នករស់រានមានជីវិត/ជនរងគ្រោះភាគច្រើនស្វែងរកការគាំទ្រផ្លូវចិត្តពីគ្រួសារ និងមិត្តភក្តិ ខណៈពេលដែលតិចជាងពាក់កណ្តាលនៃអ្នកឆ្លើយតបការស្ទង់មតិស្វែងរកជំនួយពីអាជ្ញាធរ។ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដើរតួយ៉ាងសំខាន់ដោយបានផ្តល់ជំនួយផ្នែកច្បាប់ និងប្រឹក្សាផ្លូវចិត្ត បើទោះបីជាអ្នករស់រានមានជីវិត/ជនរងគ្រោះភាគច្រើនមិនបានដឹងពីសេវាកម្មទាំងនោះក៏ដោយ។ ស្ថាប័នខ្លះមានគោលការណ៍ការពារ និងប្រព័ន្ធរាយកាណ៍ផ្ទៃក្នុង ក៏ប៉ុន្តែយន្តការបែបនេះនៅមានកម្រិត។

### ឧបសគ្គក្នុងការស្វែងរកការគាំទ្រ

រូបទី១៩៖ បញ្ហាប្រឈមដែលអ្នកមានបទពិសោធន៍ទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ (ឬអ្នកដែលគេស្គាល់)ជួបប្រទះនៅពេលស្វែងរកជំនួយ






រូបទី ២០៖ ហេតុផលដែលមិនស្វែងរកជំនួយ លើកឡើងដោយអ្នកឆ្លើយតបការស្ទង់មតិ




នៅពេលស្វែងរកជំនួយ អ្នករស់រានមានជីវិត/ជនរងគ្រោះភាគច្រើនជួបឧបសគ្គដូចជា៖ ការទទួលបានការគាំទ្រក្រៅផ្លូវការមិនស្មើគ្នា ភាពមានកម្រិតនៃប្រព័ន្ធគាំទ្រផ្លូវការ និងកង្វះខាតព័ត៌មានអំពីការស្វែងរកជំនួយ។

*“ជារឿយៗ គ្រួសាររបស់គេបានស្តីបន្ទោសឲ្យគេ។ បើទោះបីជាគេចង់ធ្វើការរាយការណ៍ ពួកគេមិនដឹងថាត្រូវទៅរកអ្នកណា ឬមិនប្រាកដថាអ្នកដទៃនឹងជឿពួកគេ។” (YL-C5)*

*“វាជាបញ្ហាពិបាក ដោយសារតែខ្ញុំមិនគិតថាមានអាជ្ញាធរណាមួយដែលអាចជួយលើរឿងនេះ (អំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ)ជាពិសេសនៅជនបទ។ (...) យើងមិនមានច្បាប់ណាមួយទាក់ទងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញ ហើយក៏មិនមានករណីណាមួយដែលអាជ្ញាធរធ្លាប់ដោះស្រាយបញ្ហានេះផងដែរ (...)។” (ZW14)*





## ព័ត៌មានពីជំនួយបច្ចេកទេស

អ្នកអាចស្វែងរកជំនួយតាមសេវាកម្មខាងក្រោម ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់បានជួបប្រទះអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលសម្របសម្រួលដោយបច្ចេកវិទ្យា។

អ្នកអាចទាក់ទងនៅពេលណាដែលអ្នកមានអារម្មណ៍ថាត្រៀមខ្លួនរួចរាល់ និងអារម្មណ៍ថាមានសុវត្ថិភាពសម្រាប់អ្នក។

### ការពារស្រ្តី

**សម្រាប់ការស្នើសុំជំនួយបច្ចេកទេស**

- លេខទូរស័ព្ទ៖ 015 404 500
- តេឡេក្រាម៖ @KarpeerWomen
- Signal: +855 15 404 500
- អ៊ីម៉ែល៖ karpeer-women@opendevcam.net

*ក្រុមការងារនឹងឆ្លើយតបក្នុងរយៈពេល ២៤ម៉ោង។

**ជំនួយបច្ចេកទេសរួមមាន៖**

- ការវាយប្រហារ ឬការបិទគណនីបណ្តាញសង្គម
- ការបៀតបៀនផ្លូវភេទ និងការរំលោភបំពានទាក់ទងនឹងយេនឌ័រតាមអនឡាញ
- ការផ្សាយព័ត៌មានឯកជនដោយគ្មានការអនុញ្ញាត
- ការប្រមាថមាក់ងាយតាមអនឡាញ/ការលួចតាមដានតាមអនឡាញ
- ការក្លែងបន្លំអត្តសញ្ញាណអនឡាញ
- ការគំរាមកំហែង ជំរិតទារប្រាក់ដោយប្រើរូបភាព ឬវីដេអូអាសអាភាស
- សម្តីស្អប់ខ្ពើម

**អ្វីដែលយើងអាចជួយបាន៖**

- ស្រោចស្រង់គណនីអនឡាញ និងគណនីបណ្តាញសង្គមឡើងវិញ
- រាយការណ៍ទៅកាន់ក្រុមហ៊ុនប្រព័ន្ធបណ្តាញសង្គម
- ឃ្លាំមើល កត់ត្រា និងវិភាគការវាយប្រហារ និងបៀតបៀនតាមបណ្តាញសង្គម

**អ្នកដែលយើងគាំទ្រ៖**

- ស្រ្តី និងកុមារី
- សហគមន៍អ្នកស្រលាញ់ភេទដូចគ្នា

klahaan

### សម្រាប់ព័ត៌មានបន្ថែម៖

គេហទំព័រ៖ https://www.klahaan.org/
អ៊ីម៉ែល៖ info@klahaan.org
Facebook: https://www.facebook.com/klahaankh/